ទម្រង់ការ ឬ នីតិវិធីធ្វើធូបទកម្មស៊ុលហ្វ៊ូរីលហ្វ្លរីដ (SULFURYL FLUORIDE)

សម្រាប់ការធ្វើធូបទកម្មដែលមានប្រសិទ្ធភាព ដំណាក់កាលនានាដូចខាងក្រោមនេះមានសារៈសំខាន់ចាំបាច់ណាស់ មុននឹ ងធ្វើធូបទកម្ម

ការត្រៀមរៀបចំផ្នែកខាងក្នុង

☐ 1. ដោះសោ និង បើករាល់ប្រដាប់ទ្រនាប់ និង ទ្វារនានាផ្នែកខាងក្នុងដែលមានជាអាទិ៍ : រោងឡាន ប្រដាប់ប្រដាប្រើប្រាស់ បន្ទប់ឃ្លាំង ទូរជាប់ជញ្ជាំង ទូរដាក់ឥវ៉ាន់ ទូរកែវ ទូរឈើនានាជាដើម ដើម្បីជួយសម្រួលដល់ខ្យល់ចេញចូលបានល្អ។ ដោយបន្ថែមលើសពីនេះទៀត យ៉ាងហោចណាស់គេត្រូវតែបើកបង្អួចមួយក្នុងមួយបន្ទប់នៃអគារតាមជាសិន មុននឹងមានការធ្វើធូបទកម្ម បើគ្មានការហាមប្រាមដោយច្បាប់រដ្ឋ ឬ ក្នុងស្រុក,មូលដ្ឋាននានាទេនោះ។

☐ 2. មនុស្សម្នាទាំងអស់ត្រូវតែចាកចេញ ហើយវត្ថុមានជីវិតទាំងអស់យកចេញឱ្យអស់ពីផ្ទះ ដែលមានប្រភេទដូចជា សត្វសំណព្វចិត្ត បក្សាបក្សី ត្រីក្នុងកែវ និង ដំណាំដាំដុះទាំងអស់។

☐ 3. របស់របរទាំងអស់សម្រាប់ការប្រើប្រាស់របស់មនុស្សដែលមានប្រភេទដូចជា ចំណីអាហារ គ្រឿងភេសជ្ជៈ ថ្នាំសង្កូវ (ដែលរួមមានរបស់របរទាំងឡាយណាដែលក្នុងទូរទឹកកក និង ទូរក្លាសេ) ដែលគ្រឿងផ្ទុកគត់ខ្យល់នានាដែលមានប្រភេទដូចជា កែវបិទជិត ឬ គ្រឿងផ្ទុកធ្វើពីដែក ត្រូវតែ: (a) មានការយកចេញពីផ្ទះមុនការធ្វើធូបទកម្ម និង (b) មានការដាក់នៅក្នុងថង់ច្រកម្ហូបអាហារ “Nylofume” ហើយមានក្ដបិទស្កុតជិត។ ចំណីអាហារដែលមិនមានការធ្វើត្រឹមត្រូវស្ថិតក្រោមការយកទៅបោះចោលដោយអ្នកធ្វើធូបទកម្មដែលមានការបញ្ជាក់ទទួលស្គាល់ត្រឹមត្រូវ។

☐ 4. យកចេញនូវពូកខ្នើយទាំងអស់ដែលមានស្រោមមិនជ្រាបទឹកដែលមានប្រភេទដូចជា ពូកនានាដែល “មិនអាចទទឹកបាន” សម្រាប់ក្មេងៗ និង បន្ទប់អ្នកជម្ងឺ។ បើស្រោមមិនជ្រាបទឹកនានាអាចសារចេញបាន វាគ្រាន់តែសំខាន់សារចេញនូវស្រោមនានាប៉ុណ្ណោះ មិនចាំបាច់យកពូកចេញទេ។ ប្រភេទពូកផ្សេងៗទៀតទាំងអស់អាចរងផលប៉ះពាល់ពីការធ្វើធូបទកម្មបាន។

☐ 5. បិទរាល់ប្រភពកម្ដៅទាំងអស់ដែលមានជាអាទិ៍ : អណ្ដាតភ្លើង និង ភ្លើងហ្គាស (ប្រដាប់កម្ដៅទឹក ចង្ក្រានហ្គាសឈុត ប្រដាប់កម្ដៅខ្យល់នៅជញ្ជាំងជាដើម)។ ចរន្តឧស្ម័ន ឬ ហ្គាសតាមបំពង់ចូលទៅតាមផ្ទះត្រូវតែមានការបិទនៅមុនកាលបរិច្ឆេទនៃការធ្វើធូបទកម្ម។ គ្រឿងដុតបញ្ចេះ និង កម្ដៅអគ្គិសនីទាំងអស់ដែលមានប្រភេទដូចជា ព្យាណូ អកជាដើម ត្រូវតែមានការបិទមុនការធ្វើធូបទកម្ម។ អ្នកនៅតាមផ្ទះបន្ទប់រៀបចំឱ្យក្រុមហ៊ុនគ្រឿងប្រដាប់ប្រដាប្រើប្រាស់បើកឧស្ម័ន ឬ ហ្គាសមកវិញ និង បន្តចាប់ផ្ដើមការយកថ្ងៃដែលបានគិតយក។

☐ 6. បិទរាល់ម៉ាស៊ីនត្រជាក់ និង ប្រព័ន្ធបញ្ជាស្វ័យប្រវត្តិសម្រាប់គ្រឿងឧបករណ៍នានា និង បណ្ដាប្រព័ន្ធប្រើភ្លើងដែលនឹងរួមមាននៅកន្លែងដែលត្រូវមានការធ្វើធូបទកម្ម។

☐ 7. ចរន្តអគ្គិសនីយត្រូវតែមានបើកទុកសម្រាប់ការបើកកង្ហារនានា។

☐ 8. បើករាល់កន្លែងចំហកន្លែងលូនដើរបាន ឬ ចន្លោះតាមក្រោមដំបូលនានា។

ការត្រៀមរៀបចំផ្នែកខាងក្រៅ

☐ 1. ទ្វារនានានៅផ្នែកខាងក្រៅត្រូវមានការចាក់សោឱ្យបានគត់មត់ដោយប្រព័ន្ធសោបន្ទាប់ដែលនឹងគ្រាន់តែមានការយកចេញដោយបុគ្គលិក Orkin ប៉ុណ្ណោះ។ ក្រុមហ៊ុន Orkin នឹងមិនទទួលខុសត្រូវចំពោះការបាក់បែកខូចខាតដែលបណ្ដាលមកពីការព្យាយាមដោះប្រព័ន្ធសោបន្ទាប់របស់អតិថិជននោះទេ។ កូនសោផ្ទះនានាត្រូវតែរក្សាទុកដោយអ្នកធ្វើធូបទកម្មដែលមានការបញ្ជាក់ទទួលស្គាល់ត្រឹមត្រូវ ឬ មានការទុកនៅតាមផ្ទះ។

☐ 2. ទម្លាក់ចុះឱ្យទាបនូវរនាំងបាំងទ្វារបង្អួចទាំងអស់នៃផ្ទះ។

☐ 3. សម្អាតចេញនូវវល្លិ៍ និង ទ្រើងនានាដែលមាននៅជាប់នឹងផ្ទះ។ ពិនិត្យគ្រឿងតែលម្អ និង ចុល្លព្រឹក្សានានាដើម្បីធានាឱ្យបានថា ក្រុមអ្នកធ្វើការងារនឹងមានចន្លោះចេញចូលបាន (ចន្លោះជាមធ្យមគ 18 អ៊ីញ) ដើម្បីទំនាក់គ្រឿងប្រដាប់បោះតង់នៅចន្លោះវា និង ផ្ទះ។

☐ 4. នៅថ្ងៃមានការធ្វើធូបទកម្មកើតឡើង អតិថិជនត្រូវតែស្រោចទឹកលើផ្ទៃដីជុំវិញផ្ទះភ្លាមៗក្នុងរង្វង់ដែលចម្ងាយប្រមាណជា 18 អ៊ីញ ហើយធ្វើមដីក្នុងរង្វង់នេះឱ្យបានជម្រៅចុះទៅក្រោមប្រវែង 8 អ៊ីញ។

☐ 5. Orkin មិនទទួលខុសត្រូវចំពោះបញ្ហាការខូចខាតទ្រព្យសម្បត្តិ ចោរលួច ឬ ការបែកបាក់ និង ការចូលមកនៅកំឡុងពេលមានការធ្វើធូបទកម្ម និង អនុវត្តទម្រង់ការបញ្ចេញបញ្ចូលខ្យល់នានាទេ។ អតិថិជនត្រឹមរៀបចំការពារសុវត្ថិភាព នៅខណៈពេលមានការទុកផ្ទះចោល។

☐ 6. ការពិនិត្យមើលហ្មត់ចត់មួយលើកន្លែងចំហកន្លែងលូនដើរបាន ឬ ចន្លោះតាមក្រោមដំបូល ត្រូវតែមានការធ្វើឡើង បើអាចចេញចូលបាន។

☐ 7. ពិនិត្យមើលលើផ្លូវខ្យល់ចេញចូលទាំងអស់ប្រយោជន៍ធានាឱ្យបានថា វាបិទជិតដើម្បីការពារកុំឱ្យសត្វសំណព្វនានាចូលបាន។

☐ 8. ប្រាប់ទៅអ្នកជិតខាងអំពីការធ្វើធូបទកម្មដែលជិតនឹងកើតមានឡើង ហើយសុំឱ្យពួកគេគ្រប់គ្រងសំណព្វចិញ្ចឹមនានារបស់ពួកគេក្នុងលក្ខណៈមួយដែលមានការទទួលខុសត្រូវខ្ពស់។

ការបញ្ចប់ធូបទកម្ម

- ដោយសារអាស្រ័យលើការបញ្ចប់ធ្វើធូបទកម្ម យើងខ្ញុំនឹងធ្វើឱ្យមានខ្យល់ចេញចូលក្នុងផ្ទះបានហ្មត់ចត់ ហើយពិនិត្យមើលវាដោយប្រើឧបករណ៍រកមើលឧស្ម័ន ឬ ហ្គាសធ្លាយរហូតដល់ផ្ទះមានសុវត្ថិភាពសម្រាប់ការចូលនៅសារជាថ្មី។
- ការចូលនៅឡើងវិញ នៅពេលដែលផ្ទះមានសុវត្ថិភាពល្អសម្រាប់ការចូលនៅឡើងវិញហើយនោះ នឹងមានការជូនដំណឹងមួយដែលបិទផ្សាយនៅលើទ្វារមុខផ្ទះ។ **មិនត្រូវចេញចូលផ្ទះទេ បើមិនមានការបិទផ្សាយសេចក្ដីជូនដំណឹងនៅលើទ្វារមុខផ្ទះដូចដែលបានលើកឡើងហើយទេនោះ។**
- ការលាងសម្អាតចាន ឆ្នាំង ខ្ទះ គ្រឿងប្រាក់ជាដើមនោះ នឹងមិនចាំបាច់ទេ ដោយសារឧស្ម័ន ឬ ហ្គាសមិនមានសំណល់ទេ។
- បុគ្គលិកការងារយើងខ្ញុំប្រកាន់យកការប្រុងប្រយ័ត្នខ្ពស់ចំពោះទ្រព្យសម្បត្តិអ្នក។ យ៉ាងណាមិញ យើងខ្ញុំមិនអាចទទួលខុសត្រូវចំពោះបញ្ហាការបាក់បែក ក្បឿងដំបូលផ្ទះ ឬ ខូចខាតដំណាំចុល្លព្រឹក្សដែលកើតមានឡើងនៅពេលកំពុងអនុវត្តទម្រង់ការ ឬ នីតិវិធីធ្វើធូបទកម្មបានទេ បើការបាក់បែកខូចខាតនេះមិនបណ្ដាលពីការធ្វើប្រហែសទាំងស្រុងរបស់ភាគីក្រុមហ៊ុន Orkin នោះ។

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានទទួលនូវសេចក្ដីជូនដំណឹងនានាអំពីការត្រៀមរៀបចំធ្វើធូបទកម្មនេះហើយ។

ហត្ថលេខាអតិថិជន ____________________ កាលបរិច្ឆេទ __________

ហត្ថលេខាអតិថិជន ____________________ កាលបរិច្ឆេទ __________